ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរសវនកម្មជាតិ
លេខ:.................អសជ/.....

# របាយការណ៍សវនកម្មលើកិច្ចប្រតិបត្តិការ




## ការត្រៀមលក្ខណៈអនុវត្ត គោលដៅអភិវឌ្ឍន៍ ប្រកបដោយចីរភាព (គ.អ.ច)

**ការិយបរិច្ឆេទពីខែមករា ឆ្នាំ២០១៦ - ខែមិថុនា ឆ្នាំ២០១៨**

អគារលេខ ៥ ផ្លូវឌួងងៀប៣ ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ
# 5, St. Duong Ngeab 3, Sangkat Tekthla, Khan Sensok, Phnom Penh, CAMBODIA
Tel:(855-23) 885 900, (855-12) 737 622 Fax: (855-23) 885 900
E-mail: naakh@naa.gov.kh website: www.naa.gov.kh

# ខ្លឹមសារសង្ខេប

*មូលហេតុ វិសាលភាព និងគោលបំណងសវនកម្ម*

សវនកម្មលើកិច្ចប្រតិបត្តិការក្រោមប្រធានបទ «ការត្រៀមលក្ខណៈអនុវត្តគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (គ.អ.ច)» ត្រូវបានជ្រើសរើសអនុវត្ត គឺដោយសារតែការអនុវត្ត គ.អ.ច ទាមទារនូវធនធានច្រើនទាំងធនធានហិរញ្ញវត្ថុ មនុស្ស និងបច្ចេកវិទ្យា។ ការត្រៀមរៀបចំបានល្អ ដូចជា ការរៀបចំស្ថាប័នបានត្រឹមត្រូវ ការសម្របសម្រួលរវាងក្រសួង ស្ថាប័ន និងការធានាបាននូវធនធានគ្រប់គ្រាន់សម្រាប់ការអនុវត្ត នឹងអាចជួយឱ្យការអនុវត្ត គ.អ.ច បានកាន់តែប្រសើរ ដែលអាចលើកស្ទួយកម្រិតជីវភាព និងសុខមាលភាពប្រជាពលរដ្ឋ ជំរុញកំណើនសេដ្ឋកិច្ច ព្រមទាំងរក្សាបាននូវបរិស្ថាន។

ការធ្វើសវនកម្មនេះនឹងវាយតម្លៃទៅលើផែនការសកម្មភាព ដែលរាជរដ្ឋាភិបាលកម្ពុជាបានរៀបចំ តាមរយៈការសម្របសម្រួលដោយក្រសួងផែនការ ជាមួយនឹងក្រសួង ស្ថាប័នពាក់ព័ន្ធ ក្នុងការត្រៀមលក្ខណៈអនុវត្ត គ.អ.ច ចាប់តាំងពីខែមករា ឆ្នាំ២០១៦ រហូតដល់ខែមិថុនា ឆ្នាំ២០១៨ នៅកម្រិតថ្នាក់ជាតិ។ ការវាយតម្លៃនេះមិនផ្តោតទៅលើការអនុវត្ត គ.អ.ច.ក ទេ គឺផ្តោតតែទៅលើការត្រៀមរៀបចំតែប៉ុណ្ណោះ។

គោលបំណងរួមនៃការធ្វើសវនកម្មនេះគឺដើម្បីវាយតម្លៃថាតើ រាជរដ្ឋាភិបាលកម្ពុជា តាមរយៈក្រសួងផែនការ ដែលជាសេនាធិការដឹកនាំ និងសម្របសម្រួល បានត្រៀមលក្ខណៈគ្រប់គ្រាន់ដើម្បីអនុវត្ត គ.អ.ច ឬទេ។ ចំពោះគោលបំណងជាក់លាក់ ការធ្វើសវនកម្មនេះ បានគ្រោងវាយតម្លៃថាតើ (១)រាជរដ្ឋាភិបាលកម្ពុជាបានដំណើរការសមាហរណកម្ម គ.អ.ច ទៅក្នុងបរិការណ៍នៃប្រទេសកម្ពុជាបានកម្រិតណា? (២)រាជរដ្ឋាភិបាលកម្ពុជាធានាបាននូវធនធានគ្រប់គ្រាន់ដើម្បីអនុវត្ត គ.អ.ច ឬទេ? និង (៣)រាជរដ្ឋាភិបាលកម្ពុជាមានរៀបចំយន្តការដើម្បីតាមដាន ត្រួតពិនិត្យឡើងវិញ និងរាយការណ៍អំពីវឌ្ឍនភាពនៃការអនុវត្ត គ.អ.ច ឬទេ?

*លទ្ធផលរកឃើញសំខាន់ៗ*

ក្រសួងផែនការបានដំណើរការសមាហរណកម្ម គ.អ.ច ទៅក្នុងបរិការណ៍ប្រទេសកម្ពុជា ដោយមានការវាយតម្លៃលើភាពស៊ីគ្នានៃផ.យ.អ.ជ និងផែនការតាមវិស័យបច្ចុប្បន្ន ធៀបទៅនឹង គ.អ.ច សាកល ក៏ប៉ុន្តែការយកលទ្ធផលបន្សុីគ្នាទៅដាក់បញ្ចូលទៅក្នុងសេចក្តីព្រាងក្របខណ្ឌ គ.អ.ច.ក នៅមានកម្រិតនៅឡើយ។ សម្រាប់ការចូលរួមដំណើរការសមាហរណកម្ម ថ្វីត្បិតតែមានក្រសួង ស្ថាប័ន ដៃគូអភិវឌ្ឍន៍ និងអង្គការមិនមែនរដ្ឋាភិបាលជាច្រើនចូលរួម តែនៅខ្វះការចូលរួមពីភាគីពាក់ព័ន្ធសំខាន់ៗផ្សេងទៀត ដូចជា ផ្នែកសិក្សាធិការ វិស័យឯកជន ថ្នាក់ក្រោមជាតិ និងប្រជាពលរដ្ឋ។ ដំណើរការធ្វើមូលដ្ឋាននីយកម្ម និងសមាហរណកម្ម គ.អ.ច ចំណាយរយៈពេលច្រើនជាងការរំពឹងទុក ហើយចំណុចដៅដែលបានជ្រើសរើសដាក់បញ្ចូលក្នុងសេចក្តីព្រាងក្របខណ្ឌ គ.អ.ច.ក នៅពុំទាន់បានពេញលេញ។

គ.ជ.នា/ក.អ.ក បានសិក្សាវាយតម្លៃលើធនធានដែលអាចមានសម្រាប់អភិវឌ្ឍន៍ប្រទេសកម្ពុជាចាប់ពីឆ្នាំ ២០១៥ រហូតដល់ឆ្នាំ២០២៥ ក៏ប៉ុន្តែធនធានទាំងអស់នោះពុំផ្តោតសម្រាប់តែការអនុវត្ត គ.អ.ច នោះទេ ហើយការប៉ាន់ស្មាននោះពុំទាន់គិតបញ្ចូលនូវប្រភពហិរញ្ញវត្ថុដែលមានលក្ខណៈនវានុវត្តន៍ផ្សេងទៀតដែរ។ ក្រៅពីនេះ ការព្យាករណ៍ពីតម្រូវការធនធានសម្រាប់អនុវត្ត គ.អ.ច តាមវិស័យនៅពុំទាន់មានការរៀបចំនៅឡើយ ចំណែកឯការបន្សុីគ្នារវាងការរៀបចំផែនការយុទ្ធសាស្ត្រថវិកា តម្រូវការវិនិយោគសាធារណៈ និងផ.យ.អ.ជ នៅមានកម្រិត។ ការស្វែងរកដៃគូដើម្បីផ្តល់ប្រភពធនធានជំនួយអភិវឌ្ឍន៍ផ្លូវការ និងធនធានពីដៃគូពីវិស័យឯកជសម្រាប់អនុវត្ត គ.អ.ច នៅពុំទាន់បានចាប់ផ្តើម ដោយនៅរង់ចាំសមាហរណកម្ម គ.អ.ច.ក ចូលទៅក្នុង ផ.យ.អ.ជ។ បញ្ហាប្រឈមពាក់ព័ន្ធនឹងធនធាន និងយុទ្ធសាស្ត្រសម្រាប់ដោះស្រាយមានបង្ហាញនៅក្របខណ្ឌ គ.អ.ច.ក ប៉ុន្តែការគ្រប់គ្រងលើហានិភ័យទាំងនោះនៅពុំទាន់បានពេញនៅឡើយ។

យន្តការសម្រាប់តាមដាន ត្រួតពិនិត្យ និងរាយការណ៍អំពីវឌ្ឍនភាពនៃ គ.អ.ច នៅពុំទាន់បានកំណត់បានច្បាស់លាស់នៅឡើយ ទោះបីជាសេចក្ដីព្រាងក្របខណ្ឌ គ.អ.ច.ក មានគម្រោងរៀបចំគណៈកម្មាធិការសម្របសម្រួល គ.អ.ច.ក។ បន្ថែមលើនេះ កង្វះទិន្នន័យធ្វើឱ្យសូចនាករនៅក្នុង គ.អ.ច.ក មិនទាន់ត្រូវបានបំបែកទៅតាម ភេទ ចំណូល អាយុ ពិការភាព ឬតំបន់ភូមិសាស្ត្រនៅឡើយដោយសារតែសមត្ថភាពមន្ត្រីស្ថិតិ និងយន្តការសម្របសម្រួលនៅមានកម្រិត។ ម៉្យាងវិញទៀត ការប្រាស្រ័យទាក់ទង និងការជំរុញឱ្យមានចូលរួមក្នុងការតាមដាន និងការពិគ្រោះយោបល់ថ្នាក់ជាតិស្ដីពី គ.អ.ច.ក ពីតួអង្គមិនមែនរដ្ឋ ដូចជា វិស័យឯកជន សង្គមស៊ីវិល ប្រជាពលរដ្ឋ និងអ្នកស្រាវជ្រាវ ជាដើមនៅពុំទាន់បានទូលំទូលាយនៅឡើយ។

*មតិរបស់ក្រសួងផែនការ*

ក្នុងការធ្វើសមាហរណកម្មរបៀបវារៈឆ្នាំ២០៣០ ទៅក្នុងបរិការណ៍ជាតិ ការសម្រេចចិត្តកំណត់ជ្រើសរើសគោលដៅ ចំណុចដៅ និងសូចនាករ ត្រូវការឱ្យមានប្រភពទិន្នន័យគាំទ្រ និងមានការឯកភាពពីក្រសួង ស្ថាប័ន ពាក់ព័ន្ធទាំងអស់ ជាពិសេស ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ ទីស្ដីការគណៈរដ្ឋមន្ត្រី គណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍកម្ពុជា និងក្រសួងផែនការ។ ការចូលរួមរបស់ភាគីពាក់ព័ន្ធក្នុងដំណើរការធ្វើមូលដ្ឋាននីយកម្មកន្លងទៅនៅមានកម្រិត ក្រសួងផែនការនឹងអញ្ជើញគ្រប់អ្នកដែលមានចំណែកពាក់ព័ន្ធ ដើម្បីចូលរួមក្នុងសកម្មភាពលើកក្រោយ ដោយគ្រោងផ្សព្វផ្សាយក្របខ័ណ្ឌ គ.អ.ច.ក នៅទូទាំងប្រទេស ប៉ុន្តែអាស្រ័យផងដែរ ទៅនឹងថវិកាគាំទ្រ។ ក្រសួងផែនការផ្ដល់អាទិភាពដល់ក្រសួង ស្ថាប័ន ដែលទទួលខុសត្រូវក្នុងការធ្វើឱ្យសម្រេចបាននូវចំណុចដៅ សូចនាករ ជាអ្នកកំណត់ជ្រើសរើស ដោយត្រូវបំពេញផងដែរជាមួយលក្ខខណ្ឌនៃការកំណត់ជ្រើសរើស ហើយការយឺតយ៉ាវគឺបណ្ដាលមកពីការសុំពន្យារពេលពីក្រសួង ស្ថាប័ន ដើម្បីព្យាយាមបំពេញតាមលក្ខខណ្ឌ ដែលក្រសួងផែនការបានកំណត់ ( SMART )។

ចំពោះធនធានសម្រាប់អនុវត្តរបៀបវារៈឆ្នាំ២០៣០ នឹងធ្វើតាមរយៈផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ចំនួនបីអាណត្តិកាល។ ក្រសួងផែនការ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ កំពុងដំណើរការប៉ាន់ស្មានថវិកាសម្រាប់អនុវត្ត ផ.យ.អ.ជ ២០១៩-២០២៣ រួមទាំងបណ្ដាគោលដៅ ចំណុចដៅ និងសូចនាករដែលបានបញ្ជ្រាបទៅក្នុង ផ.យ.អ.ជ នេះផងដែរ។ ក្រសួងផែនការ ក៏ដូចជាក្រសួង ស្ថាប័ននានារបស់រាជរដ្ឋាភិបាលកម្ពុជា នៅតែបន្តសហការ និងស្វាគមន៍ចំពោះជំនួយបច្ចេកទេស និងហិរញ្ញវត្ថុ ពីដៃគូអភិវឌ្ឍ និងព្យាយាមធ្វើឱ្យមានការពាក់ព័ន្ធពីភាគីផ្សេងៗទៀត ជាពិសេស ផ្នែកឯកជន ដើម្បីកៀរគរហិរញ្ញវត្ថុសម្រាប់អនុវត្ត គ.អ.ច.ក នេះ។

ការតាមដានត្រួតពិនិត្យនិងវាយតម្លៃ វឌ្ឍនភាពនៃការសម្រេចបាន គ.អ.ច.ក នឹងអនុវត្តនៅឆ្នាំ២០១៩ និងអាចធ្វើជារៀងរាល់ ២ឆ្នាំម្ដង អាស្រ័យលើលទ្ធភាពថវិកាគាំទ្រ និងទិន្នន័យប្រមូលបាន។ ក្រសួងផែនការកំពុងដំណើរការរៀបចំការវាយតម្លៃជាតិដោយស្ម័គ្រចិត្តឆ្នាំ២០១៩ និងរៀបចំរបាយការណ៍សម្រាប់ធ្វើបទបង្ហាញនៅអង្គការសហប្រជាជាតិនៅឆ្នាំកក្កដា ឆ្នាំ២០១៩។ ចំពោះទិន្នន័យ វិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ ជាស្ថាប័នទទួលបន្ទុកប្រមូលទិន្នន័យ សម្រាប់គាំទ្រដល់ការរៀបចំផែនការ និងការតាមដានត្រួតពិនិត្យ និងវាយតម្លៃ។ ទិន្នន័យដែលអាចមានពីមុនមក មិនមែនមានន័យថា ត្រូវតែបន្តមានរហូតនោះទេ គឺអាស្រ័យលើថវិកាជាតិ ប៉ុន្តែ បើមានលទ្ធភាពថវិកា ក្រសួងផែនការក៏អាចរៀបចំអង្កេតផ្សេងថ្មីទៀត សម្រាប់គាំទ្រដល់សូចនាករ គ.អ.ច.ក ដែលមិនបានជ្រើសរើស និងអាចដាក់បញ្ចូលក្នុងបរិការណ៍ជាតិឡើងវិញ។

*ការសន្និដ្ឋាន*

រាជរដ្ឋាភិបាលកម្ពុជាបានខិតខំប្រឹងប្រែងត្រៀមលក្ខណៈរៀបចំអនុវត្ត គ.អ.ច តាមរយៈការដឹកនាំនិងសម្របសម្រួលដោយក្រសួងផែនការ ទោះបីជាការរៀបចំនោះនៅពុំទាន់បានពេញលេញគ្រប់គ្រាន់ក៏ដោយ។ ថ្វីត្បិតតែមានកង្វះខាតមួយចំនួនក្នុងដំណើរការសមាហរណកម្ម គ.អ.ច ទៅក្នុងបរិការណ៍ជាតិ តែក្របខណ្ឌ គ.អ.ច.ក ត្រូវបានព្រាងរួចរាល់ និងត្រូវបានអនុម័តសម្រាប់ធ្វើសមាហរណកម្មចូលទៅក្នុង ផ.យ.អ.ជ។ ការកំណត់ និងការធានានូវធនធានសម្រាប់អនុវត្ត គ.អ.ច មិនទាន់បានសមស្របនៅឡើយ។ ជាមួយគ្នានេះ យន្តការតាមដានត្រួតពិនិត្យ និងរាយការណ៍អំពីវឌ្ឍនភាពនៃការអនុវត្ត គ.អ.ច នៅពុំទាន់បានរៀបចំបានពេញលេញនៅឡើយ។

*អនុសាសន៍*

ក្នុងដំណើរការធ្វើសមាហរណកម្ម គ.អ.ច ចូលក្នុងបរិការណ៍ប្រទេសកម្ពុជា ក្រសួងផែនការគួរសិក្សាពីភាគីពាក់ព័ន្ធ និងបង្កើតយុទ្ធសាស្ត្របញ្ជ្រាប និងផ្សព្វផ្សាយអំពី គ.អ.ច ដល់គ្រប់អ្នកពាក់ព័ន្ធជាពិសេស សហគមន៍មូលដ្ឋាន ប្រជាពលរដ្ឋ វិស័យឯកជន ផ្នែកសិក្សាធិការ ជាដើម។ ក្រសួងគួររៀបចំយុទ្ធសាស្ត្រសម្រាប់ការចែករំលែកព័ត៌មាន និងយន្តការទំនាក់ទំនង/ប្រាស្រ័យទាក់ទងជាមួយ ក្រសួង ស្ថាប័ន និងភាគីពាក់ព័ន្ធ និងជំរុញឱ្យមានការចូលរួមក្នុងដំណើរការសមាហរណកម្ម គ.អ.ច។ ក្រសួងផែនការក៏គួរសិក្សាតម្រូវការពង្រឹងសមត្ថភាពក្នុងការរៀបចំផែនការ និងការប្រមូលទិន្នន័យ។

ដើម្បីកំណត់ និងធានាធនធាន ក្នុងការអនុវត្ត គ.អ.ច ក្រសួងផែនការ គួរសហការជាមួយ ក.ស.ហ.វ សិក្សាស្វែងរកវិធីសាស្ត្រនវានុវត្តដើម្បីពង្រីកការកៀរគរធនធានហិរញ្ញវត្ថុបន្ថែម ផ្តល់ការណែនាំដល់ក្រសួង ស្ថាប័នឱ្យរៀបចំធ្វើការប៉ាន់ស្មានតម្រូវការធនធានហិរញ្ញវត្ថុសម្រាប់អនុវត្ត គ.អ.ច ដោយផ្សារភ្ជាប់គ្នារវាងគោលនយោបាយ ផែនការយុទ្ធសាស្ត្រថវិកា និងគម្រោងវិនិយោគសាធារណៈ។ ក្រសួងផែនការ គួរសហការជាមួយ ក.ស.ហ.វ គ.ជ.នា/ក.អ.ក និងក្រសួង ស្ថាប័នពាក់ព័ន្ធ រៀបចំឱ្យមានការកៀរគរធនធានពីតួអង្គដែលជាដៃគូអភិវឌ្ឍន៍ និងវិស័យឯកជន ហើយក្រសួងផែនការគួររៀបចំយន្តការគ្រប់គ្រងហានិភ័យនៅក្នុងក្របខណ្ឌ គ.អ.ច.ក។

ក្រសួងផែនការគួរបញ្ចូលគម្រោងបង្កើតគណៈកម្មាធិការសម្របសម្រួល គ.អ.ច.ក សម្រាប់ធ្វើការតាមដាន និងវាយតម្លៃ ជាផ្នែកមួយនៃប្រព័ន្ធតាមដាន និងវាយតម្លៃជាតិ និងគួររៀបចំកម្មវិធីបណ្តុះបណ្តាលស្តីពីការតាមដាន និងវាយតម្លៃដល់មន្ត្រីក្នុងក្រសួង ស្ថាប័នដែលត្រូវការ។ ក្រសួងផែនការ និងក្រសួង ស្ថាប័នគួរបង្កើនការសម្របសម្រួល និងការប្រាស្រ័យទាក់ទងក្នុងការផ្លាស់ប្តូរជាតុចូលសម្រាប់ការតាមដាន និងវាយតម្លៃ។ វិទ្យាស្ថានជាតិស្ថិតិ គួរពង្រឹងការសម្របសម្រួល និងការប្រាស្រ័យទាក់ទងជាមួយនឹងអង្គភាពស្ថិតិនៃក្រសួង ស្ថាប័ន និងផ្តល់ជំនួយគាំទ្រផ្នែកបច្ចេកទេសដល់មន្ត្រីស្ថិតិលើការកសាងសមត្ថភាព និងការអភិវឌ្ឍប្រព័ន្ធព័ត៌មានសម្រាប់ការប្រមូលផ្តុំ និងការគ្រប់គ្រងទិន្នន័យរដ្ឋបាល។